-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**សម្រេច**

**មាត្រា ១**.- តែងតាំងលោក **គីម អាន** ជាទីប្រឹក្សារដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

**មាត្រា ២**.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

* * *

## ២.សេចក្តីសម្រេច

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១

**សេចក្តីសម្រេច លេខ ១០ សសរ**

**ស្តីពីការបង្កើត**

**គណៈកម្មការអន្តរក្រសួង បង្ក្រាបបទល្មើស**

**គោយន្ត និងទីដេអូ ក្នុងព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យ សិល្បៈ ភាពយន្ត និងវីដេអូ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**សម្រេច**

**ប្រការ ១** : បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីត្រួតពិនិត្យ និងចាត់វិធានការបង្ក្រាបការបញ្ចាំងវីដេអូអាសអាភាស ការលក់ ឬជួល ស្លាដែភាពយន្ត និងស្លាដែវីដេអូអាសអាភាស គ្មានទិដ្ឋាការគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-លោក **ឃឹម សារិទ្ធ** | អគ្គនាយកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាប្រធាន |
| ២-លោក **សៅ ម៉ុនឈឿន** | អនុប្រធាននាយកដ្ឋានពត៌មានទូទៅ ក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៣-លោក **គង់ កន្តារ៉ា** | អនុប្រធាននាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៤-លោក **ហង់ ជួនណារិទ្ធ** | អនុប្រធានការិយាល័យ នៃនាយកដ្ឋានពត៌មានទូទៅ នៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៥-លោកវរសេនីយ៍ត្រី **សារិទ្ធ ឈុន** | នាយកដ្ឋានឃោសនាសាធារណៈ ក្រសួងការពារជាតិ | ជាសមាជិក |
| ៦-លោកវរសេនីយ៍ត្រី **រាជ សុខហេង** | នាយកដ្ឋានអធិការកិច្ចទូទៅ ក្រសួងការពារជាតិ | ជាសមាជិក |
| ៧-លោក **ចូ ម៉ុនហ៊ាង** | មន្ត្រីច្បាប់ក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៨-លោក **ទឹម សោភ័ណ** | ប្រធាននាយកដ្ឋានក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |

www.pheakdeylaw.com

៩-លោកស្រី **សាត សាលីម** អនុប្រធាននាយកដ្ឋាន ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ជាសមាជិក

១០-លោក **កែន សុគី** មន្ត្រី ក្រសួងទេសចរណ៍ ជាសមាជិក

១១-លោក **យួន សុភាព** មន្ត្រី ក្រសួងទេសចរណ៍ ជាសមាជិក

១២-លោក **គីម សារិន** មន្ត្រី ក្រសួងព័ត៌មាន ជាសមាជិក

១៣-លោក **ឈ ឈុនសៀ** មន្ត្រី ក្រសួងព័ត៌មាន ជាសមាជិក

**ប្រការ ២** : គណៈកម្មការនេះ មានភារកិច្ច :

-តាមដាន និងពិនិត្យការអនុវត្តន៍ អនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០១ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យសិល្បៈភាពយន្ត និងវីដេអូ ។

-សហការជាមួយគណៈកម្មការចំរុះ និងអាជ្ញាធរដែនដី គ្រប់ខេត្ត-ក្រុង ក្នុងការអនុវត្តន៍ អនុក្រឹត្យ សារាចរ និងលិខិតបទដ្ឋានផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យភាពយន្ត វីដេអូ ។

-តាមដាន ត្រួតពិនិត្យដើម្បីកែលំអ ពង្រឹង និងពង្រីកការងារទប់ស្កាត់បង្ក្រាប ព្រមទាំងបំបាត់ការធ្វើអាជីវកម្ម សេវាកម្ម ភាពយន្ត វីដេអូ ខារាអូខេ អនាធិបតេយ្យទូទាំងប្រទេស ។

-ចូលពិនិត្យរោងបញ្ចាំងភាពយន្ត រោងបញ្ចាំងវីដេអូ កន្លែងធ្វើអាជីវកម្មខារាអូខេ តាមស្ថានីយ៍ទូរទស្សន៍ និងទូរទស្សន៍ខ្សែកាប់ទូទាំងប្រទេស ក្នុងការចាក់បញ្ចាំងផលិតផលភាពយន្ត វីដេអូ គ្រប់ប្រភេទ ។

-ត្រួតពិនិត្យកន្លែងធ្វើអាជីវកម្ម ជួល លក់ ខ្សែភាពយន្ត កាសែ្សតវីដេអូ ឡាស៊ែរឌីស ស៊ីឌីវីដេអូ ឌីវីឌី គ្រប់ប្រភេទ លើការដាក់តាំងជួល លក់នៅតាមទីផ្សារ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

-ធ្វើកំណត់ហេតុ រៀបចំសំណុំរឿងពាក់ព័ន្ធបទល្មើស និងរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

**ប្រការ ៣** : សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ របស់ប្រធានគណៈកម្មការ ។

**ប្រការ ៤** : គណៈកម្មការអន្តរក្រសួង បង្ក្រាបបទល្មើស ភាពយន្ត និងវីដេអូ មានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**ប្រការ ៥** : សេចក្តីសំរេចលេខ ១៤ សសរ ចុះថ្ងៃទី២៩ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈ កម្មការអន្តរក្រសួង បង្ក្រាបការធ្វើអាជីវកម្ម បញ្ចាំង និងលក់ កាសែ្សតវីដេអូអាសអាភាស ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកជានិរាករណ៍ ។

www.pheakdeylaw.com

**ប្រការ ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអស់លោក លោកស្រី ដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

## III. ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០១

**ប្រកាស លេខ ១០៨ ឧរថឧ.ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ១៩១៩/០០ គ.វ.ក ចុះថ្ងៃទី ១០-៧-២០០០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

www.pheakdeylaw.com